**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ: ០៣៧/២១ សជណ.ច

ថ្ងៃអង្គារ ៦ រោច ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

រដ្ឋបាលរាជធានីភ្នំពេញ សូមជម្រាបជូនដំណឹងដល់ម្ចាស់សណ្ឋាគារ ម្ចាស់ភោជនីយដ្ឋាន ម្ចាស់ក្រុមហ៊ុននានា និងម្ចាស់អាជីវកម្មដ្ឋានគ្រប់ប្រភេទទាំងអស់ក្នុងរាជធានីភ្នំពេញឱ្យបានជ្រាបថា កន្លងមកមានបុគ្គលិកដែលបម្រើការនៅក្នុងសណ្ឋាគារ ភោជនីយដ្ឋាន ក្រុមហ៊ុននានា និងអាជីវកម្មដ្ឋានគ្រប់ប្រភេទដែលមានអាការមិនស្រួលខ្លួនក៏បានសុំការអនុញ្ញាតឈប់សម្រាកពីការងារមួយរយៈ ក្រោយពីបានធូរស្បើយពួកគាត់ក៏បានចូលបម្រើការងារវិញ ដោយពុំបានដឹងថាខ្លួនឯងមានផ្ទុកជំងឺកូវីដ-១៩ហើយមានបុគ្គលិកមួយចំនួនទៀតដែលសង្ស័យថាបានប៉ះពាល់ផ្ទាល់ ឬប្រយោលជាមួយភ្ញៀវមានផ្ទុកជំងឺកូវីដ-១៩ ក្រោយពីបានទទួលព័ត៌មាននេះ ទើបពួកគាត់បានសុំការអនុញ្ញាតឈប់សម្រាកពីការងារទៅយកសំណាកដោយខ្លួនឯងដោយពុំបានជូនដំណឹងទៅម្ចាស់អាជីវកម្មដ្ឋាន ឬអ្នកគ្រប់គ្រងនៅកន្លែងបំពេញការងារទាំងអស់ខាងលើបន្ទាប់ពីយកសំណាករួចពួកគាត់បានវិលត្រឡប់ទៅបំពេញការងារវិញជាធម្មតា និងពុំបានដាក់ខ្លួនឱ្យនៅដាច់ដោយឡែក ដើម្បីរង់ចាំលទ្ធផលពីការផ្ញើសំណាករបស់ខ្លួន ជាហេតុនាំឱ្យមានហានិភ័យខ្ពស់ក្នុងការឆ្លងរាលដាលជំងឺកូវីដ-១៩ ដល់បុគ្គលិកផ្សេងទៀតបំពេញការងារជាមួយ ពេលទទួលលទ្ធផលវិជ្ជមានកូវីដ-១៩។

ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងឈានទៅដល់ការកាត់ផ្តាច់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុង "ព្រឹត្តិការណ៍ សហគមន៍ ២០កុម្ភៈ ២០២១" រដ្ឋបាលរាជធានីភ្នំពេញស្នើសុំដល់ម្ចាស់សណ្ឋាគារ ម្ចាស់ភោជនីយដ្ឋាន ម្ចាស់ក្រុមហ៊ុននានា និងម្ចាស់អាជីវកម្មដ្ឋានគ្រប់ប្រភេទទាំងអស់ក្នុងរាជធានីភ្នំពេញ នៅពេលបុគ្គលិករបស់ខ្លួនសុំការអនុញ្ញាតឈប់សម្រាកពីការងារត្រូវផ្តល់ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទមកអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធ្វើការវាយតម្លៃស្វែងរកពីការឆ្លងកូវីដ-១៩ជូនពួកគាត់។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមម្ចាស់សណ្ឋាគារ ម្ចាស់ភោជនីយដ្ឋាន ម្ចាស់ក្រុមហ៊ុននានា និងម្ចាស់អាជីវកម្មដ្ឋានគ្រប់ប្រភេទទាំងអស់ក្នុងរាជធានីភ្នំពេញ ចូលរួមអនុវត្តតាមខ្លឹមសារខាងលើឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីឈានទៅលុបបំបាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅរាជធានីភ្នំពេញ។

(ភ្ជាប់មកជាមួយតារាងឧបសម្ព័ន្ធ)

**កន្លែងទទួល៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
  "ដើម្បីគោរពជូនជ្រាប"
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌទាំង១៤
- មន្ទីរសុខាភិបាលរាជធានីភ្នំពេញ
  "ដើម្បីមុខការ"
- គ្រប់ប្រព័ន្ធឃោសនា វិទ្យុ ទូរទស្សន៍
  "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ

## បញ្ជីរាយនាមអ្នកទទួល Lab Form នៅតាមបណ្ដាខណ្ឌទាំង១៤

| ល.រ | ខណ្ឌ | ឈ្មោះ | តួនាទី | លេខទូរស័ព្ទ |
|---|---|---|---|---|
| ១ | ចំការមន | លោក ស៊ុន សិទ្ធី | នាយករដ្ឋបាលសាលាខណ្ឌ | ០១២ ៤៥៦ ២២២ |
| ២ | ដូនពេញ | លោក ម៉ុក ចំន្ទករុណា | អភិបាលរងខណ្ឌ | ០៨៩ ៩០០ ៧៨៩ |
| ៣ | ៧មករា | លោក ម៉ប់ សារ៉េត | នាយករដ្ឋបាលសាលាខណ្ឌ | ០១២ ៩០៧ ៩២៦ |
| ៤ | ទួលគោក | លោក ហួរ ហួត | នាយករដ្ឋបាលសាលាខណ្ឌ | ០៧០ ៧៧៩ ២៥៧ |
| ៥ | ដង្កោ | លោក កេង ថា | នាយករងរដ្ឋបាលសាលាខណ្ឌ | ០១៧ ៧៨៧ ៧៧៨ |
| ៦ | មានជ័យ | លោក ឌី រ័ត្នខេមរុណា | អភិបាលរងខណ្ឌ | ០១៧ ៨១៥ ៧៥៧ |
| ៧ | ឫស្សីកែវ | លោក អ៊ុត បូរិទ្ធ | ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក | ០៨៥ ៥៥៥ ៩៩០ |
| ៨ | សែនសុខ | លោក សាំង សុគៈវិចិត្រ | អភិបាលរងខណ្ឌ | ០១១ ៨៩៨ ៨៩៨ |
| ៩ | ពោធិ៍សែនជ័យ | លោកស្រី គីម យី | នាយិការងរដ្ឋបាលសាលាខណ្ឌ | ០៩២ ៨៥៣ ៩៤៨ |
| ១០ | ជ្រោយចង្វារ | លោក កេត រតនា | នាយករងរដ្ឋបាលសាលាខណ្ឌ | ០៩៧ ៣៧០ ២២២២ |
| ១១ | ព្រែកព្នៅ | លោក ហួត លាភពិសិដ្ឋ | អភិបាលរងខណ្ឌ | ០៨៥ ៧០៧ ៧៨៨ |
| ១២ | ច្បារអំពៅ | លោកស្រី ហេង សុចន្ធា | អភិបាលរងខណ្ឌ | ០៧៧ ៧១២ ៦៦៦ |
| ១៣ | បឹងកេងកង | លោកស្រី ស៊ិន រតនា | អភិបាលរងខណ្ឌ | ០១១ ៨៣៨ ៣៦៧ |
| ១៤ | កំបូល | លោក ហោ ទាសនា | អភិបាលរងខណ្ឌ | ០១២ ៩៥២ ០៣០ |